ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ:...........................

# កំណត់ហេតុ

## កិច្ចប្រជុំឆ្លងរបាយការណ៍ប្រចាំឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២២ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃសុក្រ ប្រាំពីររោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំមួយ ត្រូវនឹងថ្ងៃទីដប់ប្រាំបួន ខែសីហា ឆ្នាំពីរពាន់ម្ភៃពីរ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសាលប្រជុំ T27 ទីស្តីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំឆ្លងរបាយការណ៍ប្រចាំឆមាសទី១ និងលើកទិសដៅ១មាសទី២ ឆ្នាំ២០២២ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដោយមានការអញ្ជើញចូលរួមពី៖

១. ឯកឧត្តម បណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
២. ឯកឧត្តម **វង សូត** រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
៣. លោកជំទាវ កិត្តិកោសល្យបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី
៤. លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
៥. ឯកឧត្តម **ស្រី សួន** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
៦. លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី
៧. ឯកឧត្តម **ហោ សារុន** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍
៨. លោកជំទាវ **ដួង សារុន** រដ្ឋលេខាធិការ ក្រសួងផែនការ
៩. លោកជំទាវ **កែវ ចរិយា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១០. លោកជំទាវ **មីន មាណវី** រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន
១១. ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌
១២. ឯកឧត្តម **សា ម៉ន** បណ្ឌិត្យ រដ្ឋលេខាធិការ ក្រសួងព័ត៌មាន
១៣. ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
១៤. ឯកឧត្តម **សុក ផេង** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី
១៥. ឯកឧត្ត **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
១៦. លោកជំទាវ **ឡាយ ណាវីន** រដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន
១៧. ឯកឧត្តម **ស៊ា កុសល** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១៨. ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ

១៩. លោកជំទាវ បណ្ឌិត សឿ សុជាតា អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា

២០. លោកជំទាវ ឡាយ វីរៈបុត្រ អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ

២១. ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ អគ្គលេខាធិការ ក្រសួងមហាផ្ទៃ

២២. លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ

២៣. លោកជំទាវ ជុំ ប្រជាប្រិយ អគ្គនាយក ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២៤. ឯកឧត្តម អ៊ុង វណ្ណៈ អធិការ ក្រសួងធម្មការ និងសាសនា

២៥. លោកជំទាវ ឧត្តមសេនីយ៍ឯក លឹម រស្មី អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

២៦. លោកជំទាវ ឧត្តមសេនីយ៍ទោ ហ៊ាង ធវី មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស

និងលោក លោកស្រីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ សរុបចំនួន ៤៤ រូប ស្រី ១៧ រូប

ជាកិច្ចចាប់ផ្តើម **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានមានប្រសាសន៍ស្វាគមន៍ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំឆ្លងរបាយការណ៍ឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ ២០២២ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ។

**សម្តេចក្រឡាហោម** មានប្រសាសន៍លើកឡើងថា គោលបំណង នៃកិច្ចប្រជុំក្នុងថ្ងៃនេះ គឺប្រជុំដើម្បីពិនិត្យ និងឆ្លងរបាយការណ៍ឆមាសទី១ និងទិសដៅឆមាសទី២ ដោយសម្តេចបានចង្អុលបង្ហាញបង្កើតផែនការប្រតិបត្តិការបន្ថែមដើម្បីបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នូវអំពើជួញដូរមនុស្ស កេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើធ្វើអាជីវកម្មផ្លូវភេទដោយសារក្រសួងការបរទេសរបស់សហរដ្ឋអាម៉េរិកបានដាក់ចំណាត់ថ្នាក់លេខ៣ មកកម្ពុជា ហើយយើងក៏ត្រូវទទួលស្គាល់ផងដែរសម្រាប់ផ្នែកខ្លះគឺពិត ក៏មានផ្នែកខ្លះមិនពិត ហើយអាចផ្នែកខ្លះស្រពេចស្រពិល ប៉ុន្តែក្នុងនាមយើងជាម្ចាស់ប្រទេស ជាម្ចាស់បញ្ហា ត្រូវពិនិត្យបញ្ហាទាំងអស់នេះឲ្យបានជាក់ស្តែង និងយកមកដោះស្រាយដើម្បីជាគុណប្រយោជន៍សម្រាប់កម្ពុជា ។ **សម្តេចក្រឡាហោម** មានប្រសាសន៍បន្តចង្អុលបង្ហាញថាពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ គណៈកម្មាធិការជាតិត្រូវចេញផែនការប្រតិបត្តិការដើម្បីពង្រឹង និងបង្កើនការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ហើយត្រូវមានយន្តការពិសេសដោយឡែកក្រៅពីក្រុមការងារទាំង៦ ដោយក្រុមការងារនេះត្រូវរាយការណ៍មកប្រធានគណៈកម្មាធិការជាតិ និងចម្លងទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងធ្វើការបូកសរុបជូនគណៈកម្មាធិការជាតិរបស់យើង ជៀសវាងមានឯកសារជាន់គ្នា ។ **សម្តេចក្រឡាហោម** មានប្រសាសន៍បន្តទៀតថា បញ្ហាជួញដូរមនុស្សយើងទាំងអស់គ្នាត្រូវទទួលស្គាល់ទាំងអស់គ្នា ហើយបើតាមការពិនិត្យជាក់ស្តែងភាគច្រើន គឺជនបរទេសបោកជនបរទេសដូចគ្នា យើងក៏បានធ្វើរឿងនេះបានផងដែរ ហើយថ្មីៗនេះក៏មានភាពមិនប្រក្រតីនៅក្នុងកាស៊ីណូជ្រៃធំរវាងបុគ្គលិកជាង ៤០នាក់ និងថៅកែរឿងប្រាក់ខែ បុគ្គលិកទាំងអស់នោះ គឺជាជនបរទេស ចិន វៀតណាម ឥណ្ឌូនេស៊ី... ខ្លះក៏ស្របច្បាប់ ខ្លះក៏មិនស្របច្បាប់ ហើយកាស៊ីណូនោះមិនដឹងថាស្របច្បាប់ ឬមិនស្របច្បាប់ផងដែរ ក្នុងករណីនេះត្រូវបង្ក្រាប ឬចុះធ្វើការសួរនាំក៏ត្រូវមានការចូលរួមពីខាងអន្តោប្រវេសន៍

អគ្គស្នងការដ្ឋាន ក្រសួងការងារដើម្បីពិនិត្យមើលប័ណ្ណការងារត្រឹមត្រូវដែរឬទេ? និងមានករណីជាច្រើនទៀតដូចជា នៅខេត្តព្រះសីហនុ ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អញ្ជើញធ្វើសេចក្តីរាយការណ៍ដោយសង្ខេបអំពីសកម្មភាពរបស់ក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០២២ ជូន សម្តេចក្រឡាហោមប្រធានអង្គប្រជុំ និងឯកឧត្តម លោកជំទាវ លោក លោកស្រីជាសមាជិក សមាជិកា អង្គប្រជុំ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍កោតសសើរដល់ក្រុមការងារ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់ និងអគ្គលេខាធិការដ្ឋាន ដែលបានខិតខំបំពេញតួនាទីរបស់ខ្លួនអស់ពីកម្លាំងកាយចិត្តទោះបីយើងមិនទទួលបានលទ្ធផលល្អក៏ដោយ ប៉ុន្តែតាមរយៈរបាយការណ៍នេះ បង្ហាញថាយើងបានអនុវត្តសម្រេចបានលទ្ធផលល្អប្រសើរជាច្រើន ទោះបីជាមានការសេសសល់ការងារខ្លះក៏ដោយ ប៉ុន្តែយើងនឹងបន្តធ្វើរហូត ។ **សម្តេចក្រឡាហោម** មានប្រសាសន៍ស្នើដល់ក្រុមការងាររបាយការណ៍ នៃអគ្គលេខាធិការដ្ឋានរៀបចំទម្រង់របាយការណ៍សង្ខេបខ្លីជាងនេះ កុំឲ្យវែងពេកកុំឲ្យលើសពី១០ទំព័រ បើអាចពង្រីកអក្សរឲ្យធំជាងនេះបន្តិច អាចដាក់ទៅតាមក្រុមការងារនីមួយៗ ក្រុមការងារណាធ្វើបានអ្វី? និងមិនទាន់បានធ្វើអ្វី? យើងធ្វើពីរ មួយជារបាយការណ៍សង្ខេបសម្រាប់ធ្វើការផ្សព្វផ្សាយ និងមួយទៀតជារបាយការណ៍លម្អិតសម្រាប់តម្កល់ទុក និងមិនចាំបាច់មានចំណុចច្រើនពេកទេ ចុងបញ្ចប់ត្រូវមានកាលបរិច្ឆេទសម្រេច និងមានការចម្លងជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ចំពោះចំណុច (ទិសដៅបន្ត) យើងគួរដាក់ថា (ការប្តេជ្ញាចិត្ត) ឧទាហរណ៍៖ ក្នុងស្ថានភាពមានការជួញដូមនុស្សនៅកម្ពុជាកំពុងមានភាពស្មុគស្មាញ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមប្តេជ្ញាចិត្ត..... រកពាក្យឬឃ្លាណាមួយដែលបង្ហាញអំពីសកម្មភាពរបស់យើង ដែលអនុវត្តទទួលបានជោគជ័យ ដើម្បីទាញយកចំណាត់ថ្នាក់ល្អសម្រាប់កម្ពុជាវិញ ។ **សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់អំពីការប្រើប្រាស់ពាក្យពេចន៍ឲ្យសមស្របទៅនឹងសកម្មភាព ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថា (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនឹងដាក់ចេញនូវផែនការ ស្តីពី កិច្ចសហប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ) យើងមិនចាំបាច់និយាយអ្វីច្រើនពេកទេកុំឲ្យមានការប៉ះពាល់ដល់បញ្ហានយោបាយ ។

**ឯកឧត្តម បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំឆ្លងរបាយការណ៍ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយ ឯកឧត្តម មានប្រសាសន៍ឯកភាព និងគាំទ្រប្រសាសន៍ដឹកនាំរបស់ សម្តេចក្រឡាហោម ប្រធានអង្គប្រជុំពាក់ព័ន្ធទម្រង់របាយការណ៍ សូមឲ្យសម្រួលឲ្យខ្លី យើងក៏ទទួលស្គាល់ថារបាយការណ៍លម្អិតនេះ គឺល្អគ្រប់គ្រាន់ ប៉ុន្តែយើងគួររៀបជាតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយវិញ ។ ឯកឧត្តម មានប្រសាសន៍ឯកភាពនូវរាល់ទិដ្ឋភាពសកម្មភាពគ្រប់ក្រសួង ស្ថាប័នទាំងអស់ចំណុះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលយើងបានខិតខំប្រឹងប្រែងអនុវត្តទៅតាមផែនការដែលបានដាក់ចេញកន្លងមក ចំណែកអគ្គលេខាធិការដ្ឋានក៏បានដើរតួនាទីសម្របសម្រួលបានយ៉ាងល្អ ក៏ដូចជាក្រុមការងារទាំង៦ ដែលមានក្រសួង ស្ថាប័នទាំង៦ ជាអ្នក

ដឹកនាំ ក៏បានបំពេញតួនាទីភារកិច្ចអនុវត្តទៅតាមផែនការដែលបានដាក់ចេញរបស់ថ្នាក់ដឹកនាំផងដែរ ។ ឯកឧត្តម ក៏មានប្រសាសន៍គាំទ្រដែលសម្តេចក្រឡាហោម បានដាក់ចេញនូវទិសដៅបង្កើតផែនការប្រតិបត្តិការក្នុងការបង្កើន ការយកចិត្តទុកដាក់ប្រឆាំងគ្រប់ទម្រង់ នៃការជួញដូរមនុស្សនៅកម្ពុជា ដោយយើងសង្កេតឃើញថាមានបញ្ហាថ្មីៗជា ច្រើនដែលយើងត្រូវដោះស្រាយ ហើយយើងក៏មានការសោកស្តាយដែលសហរដ្ឋអាម៉េរិកបានធ្វើការវាយតម្លៃផ្តល់ចំ ណាត់ថ្នាក់លេខ៣ ក្នុងបញ្ជីខ្មៅ នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលយើងមិនធ្លាប់បានជួបប្រទះពីមុន មក ។ ឯកឧត្តម មានប្រសាសន៍បន្តថា នៅក្នុងអនុសាសន៍ទាំង១៧ របស់សហរដ្ឋអាម៉េរិកដែលបានផ្ញើមកកម្ពុជា ដកចេញ១ចំណុច នៅសល់ ១៦ គឺមានចំនួន ៨ចំណុច ពាក់ព័ន្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានរៀបចំរួចហើយដែរ ពាក់ព័ន្ធចំណុចទាំង៨នេះ ក្នុងនាមក្រុមការងារ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នឹងគោរពស្នើសុំអនុសាសន៍ពីសម្តេចដើម្បីពិនិត្យ លើកឡើងនូវវិធានការដាក់ស្តែងនានា ក្នុង នោះមានការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការរៀបចំយន្តការ និងវិធានការនានាដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ ទាំង១៦ នេះ ។ ឯកឧត្តម មានប្រសាសន៍បន្តថា ស្របពេលប្រទេសកម្ពុជាបច្ចុប្បន្នមានការរីកចម្រើន មានសក្តានុ ពល មានសន្តិភាព ធ្វើឲ្យមានការវិនិយោគគ្រប់វិស័យដែលបានផ្តល់ឱកាសការងារជាច្រើនដល់ប្រជាជនកម្ពុជា និងបាន ផ្តល់ឱកាសក្នុងការចល័តចេញ/ចូលកម្លាំងពលកម្ម ពីក្រៅមកយើង ពីយើងចេញទៅក្រៅ ហើយក៏មានក្រុមហ៊ុនខ្វះ ខ្វះកម្លាំងពលកម្មត្រូវបានជ្រើសរើសដោយខ្លួនឯង រហូតមានការស្នើសុំដល់ថ្នាក់ដឹកនាំទៀតផង ហើយក៏មានការ គេចវេសពីសមត្ថកិច្ចអន្តោប្រវេសន៍ចូលមកធ្វើការនៅកម្ពុជា តាមរយៈការមកទេសចរណ៍ជាដើម ពួកគេទាំងអស់ នោះភាគច្រើនធ្វើការនៅក្នុងកាស៊ីណូ និងសហគ្រាសផ្សេងៗទៀត ហើយអ្វីដែលគួរឲ្យកត់សម្គាល់ គឺការចូលមកកម្ពុជា តាមយន្តហោះភាគច្រើន គឺជនជាតិឥណ្ឌា បង់ក្លាដេសជាដើម មិនមែនមកវិនិយោគ ឬទេសចរណ៍ទេ គឺមកធ្វើការ នៅប្រទេសកម្ពុជាក៏អាចថាបានដែរ ។ ឯកឧត្តម មានប្រសាសន៍បន្ថែមថា មានការស្នើសុំពីអគ្គរដ្ឋទូតរបស់ប្រទេស គាត់ បានធ្វើស្នើសុំឲ្យមានការបញ្ជូនកម្លាំងពលកម្មទៅធ្វើការនៅប្រទេសរបស់គាត់ ដូចជាថៃ និងម៉ាឡេស៊ី ចំពោះ ប្រទេសកូរ៉េ និងជប៉ុន យើងកំពុងបន្តកិច្ចសហការបញ្ជូនទៅ ចំពោះប្រទេសមួយចំនួនដែលមាន MOU ជាមួយគ្នា ដូចជាប្រទេសអារ៉ាប៊ីសាអូឌីដ កាតា មិនមានអ្នកចង់ទៅធ្វើការនៅទីនោះទេ ស្របគ្នានេះដែរក៏មានប្រទេសដែលចង់ បញ្ជូនមកដែរ គឺប្រទេសបង់ក្លាដេស ដោយប្រទេសគាត់តូចជាងយើង ចំនួនប្រជាជនច្រើន តម្លៃទីផ្សារការងារទាប ប្រហែល ៧០ ទៅ៨០ ដុល្លារសហរដ្ឋអាម៉េរិក ពេលមកដល់យើងគាត់ទទួលបានជាង២០០ ដុល្លារ ដូច្នេះគាត់ សម្លឹងឃើញយើងជាទីផ្សារការងាររបស់គាត់ ។ ឯកឧត្តម មានប្រសាសន៍បញ្ជាក់អំពីការបញ្ជូនកម្លាំងពលកម្មចេញ ទៅធ្វើការនៅក្រៅប្រទេសស្របច្បាប់តាមរយៈទីភ្នាក់ងារ ក្នុងមួយខែមានចំនួនពី ៨,០០០នាក់ ទៅ ១០,០០០នាក់ ហើយក៏មានការចូលមកវិញមានចំនួនប្រហាក់ប្រហែលគ្នា ចំពោះការចេញទៅប្រទេសថៃតាមរយៈ Border Past ចេញព្រឹកចូលល្ងាចមានន័យថាស្របច្បាប់ ហើយក៏មានការចេញទៅដោយមិនស្របច្បាប់ផងដែរ ប៉ុន្តែក្នុងពេលរីក រាលដាល នៃជំងឺកូវីដ-១៩ ក្រសួងការងារ និងអាជ្ញាធរថៃបានចេញលិខិតការងារស្របច្បាប់ដល់ពលករដែលកំពុង ធ្វើការនៅប្រទេសថៃ បច្ចុប្បន្នបើយើងទៅរកពលករខ្មែរមិនស្របច្បាប់ គឺប្រហែលជាគ្មានទេ ពីព្រោះបើគេដឹងថាមាន ពលករណាមិនស្របច្បាប់ក្រសួងការងារ និងអាជ្ញាធរថៃធ្វើឲ្យភ្លាម ដោយសារគេត្រូវការកម្លាំងពលកម្មជាច្រើន ចំពោះការផ្តល់ភាពស្របច្បាប់ជូនពលករ គឺយើងធ្វើនៅក្នុងប្រទេសដោយសារខាងថៃគេបានធ្វើការងារនេះហើយ យើងធ្វើសម្រាប់ពលរដ្ឋយើងចង់ទៅដោយស្របច្បាប់ និងពន្យាពេល គឺអាចមកធ្វើនៅព្រំដែនបាន មាននៅបាត់

ដំបង ប៉ោយប៉ែត និងនៅភ្នំពេញ ។ ឯកឧត្តម បានលើកឡើងអំពីចំណុចមួយក្នុងអនុសាសន៍របស់សហរដ្ឋអាម៉េរិក ទាំង១៦ គឺការយកកម្រៃពីពលករមុនពេលបញ្ជូនទៅក្រៅប្រទេស បញ្ហានេះកំពុងតែពិនិត្យ ស្រាវជ្រាវករណីនេះ រៀបចំទប់ស្កាត់ និងរៀបចំបទបញ្ញត្តិឲ្យបានត្រឹមត្រូវ បង្កើតតារាងកំណត់ថ្លៃសេវាសម្រាប់ភ្នាក់ងារផ្លូវការរបស់យើង ក្នុងការជ្រើសរើស និងបញ្ជូនពលករ ចំពោះបញ្ហាយកម្រៃមុន គឺក្រសួងមិនអនុញ្ញាតឡើយ ។ ឯកឧត្តម មានប្រសាសន៍ពាក់ព័ន្ធនឹងប្រភេទពលកម្មកុមារ ក៏ចាត់ទុកជាប្រភេទ នៃអំពើជួញដូរមនុស្សដែរ ពាក់ព័ន្ធនឹងអនុសាសន៍ ក៏បានលើកឡើងផងដែរដោយសហរដ្ឋអាម៉េរិកបានលើកឡើងដោយផ្អែកលើប្រព័ន្ធផ្សព្វផ្សាយ ពេលក្រុមការងារចុះទៅពិនិត្យបូជាមិនមាន ឬមួយបន្ទាប់ពីការផ្សាយរួចហើយពួកគាត់គេចខ្លួនយើងក៏មិនដឹង ឥឡូវខាងសហរដ្ឋអាម៉េរិក ចេញអនុសាសន៍ឲ្យយើងចុះទៅដោយមិនប្រាប់មុន យើងនឹងធ្វើតាមគាត់លើរឿងនេះ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍អរគុណ និងឯកភាពប្រសាសន៍របស់ **ឯកឧត្តម បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានលើកឡើងពាក់ព័ន្ធនឹងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបាយការណ៍សំខាន់ៗដែលក្រសួងបានខិតខំអនុវត្តកន្លងមក ។ សម្តេចក្រឡាហោម មានប្រសាសន៍ស្នើ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ពិនិត្យ ដាក់បញ្ចូលទៅក្នុងចំណុច(ខ.ការបង្ការទប់ស្កាត់) ករណីចូលមកធ្វើការនៅកម្ពុជា ពីជនជាតិបរទេស ជាពិសេសបង់ក្លាដេស ឥណ្ឌា ស្តីពី ពង្រឹងការគ្រប់គ្រង ការផ្តល់ទិដ្ឋាការ ដល់ជនបរទេសឲ្យបានម៉ត់ចត់ ហើយក្រសួងការងារក៏ពាក់ព័ន្ធនឹងការផ្តល់ប័ណ្ណការងារឲ្យពួកគាត់ដែរ នេះគឺជាផ្នែកមួយ នៃការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ។ សម្តេចក្រឡាហោម បានមានប្រសាសន៍បន្តថា កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ សម្តេចបានដឹកនាំកិច្ចប្រជុំចង្អៀតមួយ ស្តីពីការបង្កើតផែនការប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលសេចក្តីព្រាងនេះបានរៀបចំឡើងដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ហើយយើងបានសិក្សា និងបញ្ចូលនូវផែនការសកម្មភាព ស្តីពីការប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២-២០២៣ សម្រាប់កម្ពុជាដែលភាគីសហរដ្ឋអាម៉េរិកបានលើកឡើងទាំង១៦ចំណុច យើងបានបញ្ចូលចំនួន ០៨ ចំណុច នៅសល់ ០៨ចំនណុចទៀត សូមក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យចាត់ចែងដោយឡែកសិន ។ យើងក៏បានប្រជុំអនុគណៈកម្មការអនុវត្តច្បាប់ ដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធាន អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អនុប្រធាន កងរាជអាវុធហត្ថលើផ្ទៃប្រទេសអនុប្រធាន អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន ដោយឡែកក្រសួងមួយចំនួន ចាត់តំណាង សម្តេចមានប្រសាសន៍ស្នើឲ្យក្រសួងពាក់ព័ន្ធចាត់ឲ្យចំឈ្មោះ កុំឲ្យម្តងអ្នកនេះមក ម្តងអ្នកនោះមក ធ្វើឲ្យការងារមិនច្បាស់លាស់ និងគ្មានប្រសិទ្ធភាព ។ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះផងដែរ **សម្តេចក្រឡាហោម** មានប្រសាសន៍ថាមានតំណាងអង្គការសហប្រជាជាតិបានសុំជួបសំណេះសំណាលការងារជាមួយ **លោកជំទាវ ជូ ប៊ុនអេង** ប៉ុន្តែសម្តេចមិនទាន់អនុញ្ញាតឲ្យជួបពីព្រោះយើងមិនទាន់មានឯកសារគ្រប់គ្រាន់ការប្តេជ្ញាចិត្ត ឥឡូវយើងមានហើយ ដូច្នេះអាចជួបជាមួយតំណាងអង្គការសហរដ្ឋអាម៉េរិកបានហើយ ។

**លោកជំទាវ កិត្តិកោសល្យបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី មានប្រសាសន៍នៅក្នុងកិច្ចប្រជុំនេះថា ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីសម្តេចក្រឡាហោម ឲ្យមានការជួបពិភាក្សាការងារជាមួយ

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ដោយមាន លោកជំទាវផ្ទាល់ និងលោកជំទាវ ជូ ប៊ុនអេង ពេលនោះ ឯកឧត្តម ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា បានកោតសរសើរចំពោះការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាល និងក្រោមការដឹកនាំផ្ទាល់របស់ **សម្តេចក្រឡាហោម** បានខិតខំអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកន្លងមកយ៉ាងលំបាក ប៉ុន្តែអ្វីដែលបានខិតខំនេះ គឺមិនទាន់បានគ្រប់ជ្រុងជ្រោយ មិនច្បាស់លាស់ មិនស៊ីចង្វាក់ទៅនឹងរបាយការណ៍ដែលបានផ្ញើមកអាមេរិក មិនទាន់ត្រូវចំណុចដែលគេចង់បាន អ្វីដែលសហរដ្ឋអាមេរិកចង់បាន គឺការបង្ក្រាបបទល្មើស និងចាប់ជនល្មើសមកផ្តន្ទាទោស ហើយខាងសហរដ្ឋអាមេរិកក៏បានលើកឡើងពាក់ព័ន្ធក្រសួងយុត្តិធម៌ លើការងាររៀបចំទម្រង់ទិន្នន័យមានលក្ខណៈខុសគ្នា ដែលធ្វើឲ្យគេពិបាកប្រៀបធៀបលទ្ធផលការងារ គណៈប្រតិភូសហរដ្ឋអាមេរិកបានស្នើមកកម្ពុជាថា ធ្វើយ៉ាងណាមានរបាយការណ៍ច្បាស់លាស់ចំគោលដៅ ហើយក៏មានការពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ ក៏មិនមានទិន្នន័យច្បាស់លាស់លើសុំណុំរឿង និងដំណើរការផ្តន្ទាទោសជនល្មើសក៏មិនច្បាស់លាស់ផងដែរ និងមួយទៀត គឺការចុះធ្វើអធិការកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមិនជូនដំណឹងមុនដល់រោងចក្រ សហគ្រាសជាដើម ស្នើឲ្យមានការរំលេចការងារនេះនៅក្នុងរបាយការណ៍ផង បញ្ហាមួយទៀត គឺគេស្នើឲ្យយើងរំលេចអំពីចំណាយធនធាន ថវិកា ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពាក់ព័ន្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមាននៅក្នុងអនុសាសន៍ទី២ និងទី៤ ។ លោកជំទាវ មានប្រសាសន៍បន្ថែមថា ខាងសហរដ្ឋអាមេរិកក៏បានស្នើឲ្យមានកិច្ចប្រជុំប្រចាំឆ្នាំជាមួយគ្នា និងស្នើឲ្យមានការបង្កើតយុទ្ធសាស្ត្រថ្មី ដើម្បីបង្កើនប្រសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជា សហរដ្ឋអាមេរិក គឺមិនមានការលាយឡំជាមួយបញ្ហានយោបាយទេ ហើយខាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា បានលើកឡើងថាគាត់ក៏បានស្នើសុំឲ្យមានការយោគយល់ពីទីក្រុងវ៉ាស៊ីនតោនដែរ ប៉ុន្តែក្រុងវ៉ាស៊ីនតោនមិនយល់ព្រម គឺជាគោលការណ៍របស់គេ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍អរគុណដល់ **លោកជំទាវ រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី** មានប្រសាសន៍អំពីកិច្ចខិតខំប្រឹងប្រែងលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានលើកឡើងអំពីការស្នើរបស់សហរដ្ឋអាមេរិកពាក់ព័ន្ធអនុសាសន៍ទាំង១៦ ដូចជាបញ្ហាការចំណាយថវិកាលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បញ្ហានេះ គឺទុកឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកបកស្រាយ បំភ្លឺតាមជំនាញ ។ សម្តេច មានប្រសាសន៍បន្តថា ចំពោះបញ្ហាថវិកាលើការងារនេះ គួរតែមានទោះបីជាមិនមានលើសលប់ ក៏ត្រូវមានខ្លះដែរ សូមតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួយនាំបញ្ហានេះជម្រាបជូន ឯកឧត្តម ឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផង បញ្ហាមួយទៀតពាក់ព័ន្ធក្រសួងយុត្តិធម៌ សូមនាំបញ្ហានេះជម្រាបជូន ឯកឧត្តម រដ្ឋមន្ត្រី ពាក់ព័ន្ធចំនួនការផ្តន្ទាទោសជនល្មើស និងទម្រង់របាយការណ៍ ។ **សម្តេចក្រឡាហោម** មានប្រសាសន៍លើកឡើងអំពីការស្នើសុំឲ្យមានកិច្ចប្រជុំរវាងកម្ពុជា និងសហរដ្ឋអាមេរិក ដោយសម្តេចបានឯកភាពឲ្យមានកិច្ចប្រជុំ សំខាន់យើងត្រូវត្រៀមរបាយការណ៍ឆ្លើយតបទៅនឹងអនុសាសន៍ទាំង១៦ និងអ្វីដែលគេចង់បាន ស្រាវជ្រាវរកយុទ្ធសាស្ត្រ ក៏ដូចជាផែនការការងារសម្រាប់ប្រតិបត្តិការ ស្វែងរកការគាំទ្របន្ថែម យើងស្នើទៅសហរដ្ឋអាមេរិក គួរតែបើកកិច្ចប្រជុំដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធបានអត់? **សម្តេចក្រឡាហោម** បានស្នើឲ្យអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ

ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជួយសម្របសម្រួល រៀបចំឲ្យមានកិច្ចប្រជុំនេះឡើងជាមួយដៃគូពាក់ព័ន្ធ សូមត្រៀមរៀបចំ និងសម្រួលរបាយការណ៍ឡើងវិញ សម្តេចនឹងចុះហត្ថលេខាលើរបាយការណ៍កិច្ចប្រជុំថ្ងៃនេះក្នុងនាមជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីព្រោះសមាជិកក៏មានរដ្ឋមន្ត្រី ក្រសួងមួយចំនួនផងដែរ ហើយរបាយការណ៍នេះក៏ត្រៀមបង្ហាញសម្រាប់កិច្ចប្រជុំជាមួយដៃគូអំពីលទ្ធផលការងារដែលយើងបានធ្វើ និងទិសដៅយើងត្រូវធ្វើបន្ត ដើម្បីឆ្លើយតបឲ្យចំគោលដៅ នៃអនុសាសន៍ដែលសហរដ្ឋអាម៉េរិកចង់បាន ដោយមានការរៀបចំជា Slide និងបញ្ហាមួយទៀតពាក់ព័ន្ធការបង្ក្រាបបទល្មើសជួញដូរ គឺជាការងាររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ។

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន** អគ្គស្នងការនគរបាលជាតិ មានប្រសាសន៍នៅក្នុងកិច្ចប្រជុំនាពេលនេះថា គាំទ្រប្រសាសន៍ដឹកនាំដ៏ឈ្លៀសវៃរបស់ **សម្តេចក្រឡាហោម** និងប្រសាសន៍របស់ ឯកឧត្តម លោកជំទាវ ដែលមានប្រសាសន៍ក្នុងកិច្ចប្រជុំថ្ងៃនេះ ។ ឯកឧត្តម បានមានប្រសាសន៍បន្ថែមពាក់ព័ន្ធរបាយការណ៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺ ទី១. ការបង្ហាញឲ្យឃើញអំពីស្ថានការ និងលទ្ធផលប្រតិបត្តិការរបស់យើង ទី២. ទិសដៅ ដែលបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់យើង ដោយផ្តោតទៅអ្វីដែលជាការពិត ការចោទរបស់គេមកលើយើង អ្វីដែលជាកិច្ចខិតខំប្រឹងប្រែងរបស់យើង និងអ្វីដែលជាការទទួលខុសត្រូវរបស់យើង នោះទើបគេឲ្យតម្លៃមកយើង ក្នុងនាម ឯកឧត្តម ជាអគ្គស្នងការនគរបាលជាតិ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមចូលរួមជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ កែសម្រួលរបាយការណ៍នេះ ហើយបញ្ហាមួយទៀត គឺអនុសាសន៍ទាំង១៦ របស់សហរដ្ឋអាម៉េរិក តាមការសង្កេតលើអនុសាសន៍ទាំងអស់នេះ មានភាពលាយលំជាមួយបញ្ហានយោបាយ ហាក់ដូចជាមានការជ្រៀតជ្រែកផ្ទៃក្នុងកម្ពុជា ពាក់ព័ន្ធនឹងអធិតេយ្យរបស់កម្ពុជា គេចង់ឲ្យយើងធ្វើការងារតាមទម្រង់របស់គេ ដែលយើងមិនអាចទទួលយកបានទើបយើងទទួលយកតែ៨ចំណុច ក្នុងចំណោមអនុសាសន៍ទាំង១៦ ។ **ឯកឧត្តម** មានប្រសាសន៍បញ្ជាក់ថា ក្នុងនាមអគ្គស្នងការនគរបាលជាតិបានធ្វើការជាមួយសហរដ្ឋអាម៉េរិកចំនួន ៤ អង្គភាព ប៉ុន្តែយើងនៅតែមិនទទួលលទ្ធផលល្អដដែល ហើយយើងក៏បានសម្តែងការមិនសប្បាយចិត្តជាមួយគាត់ដើម្បីឲ្យគាត់យល់ យើងនៅតែបន្តធ្វើ គាត់បានឆ្លើយថាការដាក់ពិន្ទុរបស់សហរដ្ឋអាម៉េរិក គឺគេមិនបានសួរខាង FBI ដែលធ្វើការនៅប្រទេសកម្ពុជា ។ ឯកឧត្តម បានលើកឡើងបន្តថា នៅក្នុងរបាយការណ៍យើងគួរតែរំលេចនូវស្នាដៃ លទ្ធផលការងាររបស់អង្គការដៃគូខ្លះផងដែរ ពីព្រោះគាត់ក៏បានចូលរួមសហការជាមួយយើង ជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បញ្ហានេះក៏ជាមូលហេតុ នៃការទទួលលទ្ធផលមិនល្អដែរ ហើយយើងទាំងអស់គ្នាត្រូវការពារស្នាដៃរបស់យើង ត្រូវរកយុត្តិធម៌សម្រាប់ខ្លួនឯងពីព្រោះមានចំណុចខ្លះមិនមែនជាការពិតដែលគេបានចោទមកលើយើង ។ ឯកឧត្តម មានប្រសាសន៍រាយការណ៍សង្ខេបជូន សម្តេចក្រឡាហោម ប្រធានអង្គប្រជុំអំពីលទ្ធផលការងារ ក្នុងរយៈពេល ៧ខែដើមឆ្នាំ ២០២២ អគ្គស្នងការដ្ឋាននគរបាលជាតិដោះស្រាយបណ្តឹងជនបរទេសចំនួន ៦០ ករណី និងបានរំដោះជនបរទេសចំនួន ជាង ៦០០ នាក់ មានចំនួន ១៧ ករណីក្នុង៦០ករណី គឺជាការបង្ខាំង ជម្រិត ដែលយើងប្តឹងទៅតុលាការដើម្បីផ្តន្ទាទោស ក្រៅពីនោះជាករណីទំនាស់ការងារ ការផ្លាស់ប្តូរការងារ ការរិតត្បិតក្នុងកន្លែងការងារ ការជំពាក់បំណុលការងារជាដើម... ប៉ុន្តែសហរដ្ឋអាម៉េរិកវាយតម្លៃគេមិនយកតាមយើងទេ គឺគេយកតាមព័ត៌មានដោយ

មិនពិតប្រាកដ មិនសមហេតុផល និងតាមរយៈការរាយការណ៍ពី NGO... ដូច្នេះយើងត្រូវដឹងអំពីហេតុផលទាំងអស់នេះ សម្រាប់កម្ពុជាការប្តេជ្ញាចិត្ត គឺជំណាស់លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីព្រោះប្រទេសយើងគឺរាជរដ្ឋាភិបាលទាំងមូលមាន សម្តេចក្រឡាហោមជាប្រធានគណៈកម្មាធិការជាតិ ដែលសម្តេចដឹកនាំដោយភាពទន់ភ្លន់ និងមានរដ្ឋមន្ត្រីក្រសួងមួយចំនួនជាអនុប្រធាន និងជាសមាជិក នេះគឺជាយន្តការរបស់កម្ពុជា ចំពោះប្រទេសដទៃវិញមានតែអនុប្រធាននគរបាលតែប៉ុណ្ណោះដឹកនាំធ្វើការងារនេះ ។ **ឯកឧត្តម** មានប្រសាសន៍ឯកភាព និងគាំទ្រប្រសាសន៍សម្តេចក្រឡាហោម អំពីការបង្កើតផែនការប្រតិបត្តិការប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ ដោយមានអគ្គស្នងការនគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាក់ព័ន្ធ ។ **ឯកឧត្តម** បានមានប្រសាសន៍បញ្ជាក់ជូនសម្តេចបន្ថែមថា ចំពោះការងារនេះ ឯកឧត្តម បានពិភាក្សាជាមួយ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍រួចហើយអំពីផែនការ នៃការស្រាវជ្រាវ រឹតបណ្តឹងចំពោះជនបរទេសចូលមក និងរស់នៅក្នុងប្រទេសកម្ពុជា ចំពោះសមាសភាពក្រុមការងារនេះនឹងរៀបចំឲ្យបានឆាប់រហ័សដើម្បីដាក់ជូន សម្តេចចុះហត្ថលេខា បន្ទាប់មក ឯកឧត្តម នឹងកោះអញ្ជើញសមាជិកទាំងអស់មកជួបប្រជុំពិភាក្សាគ្នាអំពីផែនការការងារនេះ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍អរគុណ និងគាំទ្រចំពោះប្រសាសន៍លើកឡើងរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ហើយសម្តេចក៏បានបញ្ជាក់ម្តងទៀតអំពីការជួយសហការកែសម្រួលទម្រង់របាយការណ៍របស់យើងឲ្យបានម៉ត់ចត់ ក្នុងការត្រៀមជួបប្រជុំជាមួយដៃគូ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កម្ពុជា ហើយអ្វីដែលសំខាន់ គឺយើងត្រូវត្រៀមទឡ្ហីករបកស្រាយទាក់ទងទៅនឹងអនុសាសន៍ដែលយើងបានជ្រើសរើសទាំង៨ ក្នុងចំណោម១៦ ។ សម្តេចក្រឡាហោម ស្នើឲ្យមានការអញ្ជើញស្ថានទូតដែលជាដៃគូ តំណាងអង្គការសហប្រជាជាតិ អង្គការដៃគូពាក់ព័ន្ធនានា សូមឲ្យរៀបចំបញ្ជីឈ្មោះឲ្យបានច្បាស់លាស់ តើត្រូវអញ្ជើញចំនួនប៉ុន្មានមកចូលរួមកិច្ចប្រជុំ ។

**សម្តេចក្រឡាហោម** ប្រធានអង្គប្រជុំ មានប្រសាសន៍បូកសរុបលទ្ធផល នៃកិច្ចប្រជុំឆ្លងឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដូចខាងក្រោម៖

១.រៀបចំកែសម្រួលរបាយការណ៍ជួញដូរមនុស្សឡើងវិញ ចំណុចដែលនៅសេសសល់ទុកធ្វើជាឧបសម្ព័ន្ធ

២.លើកទិសដៅ ស្តីពីការប្តេជ្ញាចិត្តរបស់កម្ពុជាលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៣. ការគ្រប់គ្រង និងការផ្តល់វីសាដល់ជនបរទេសឲ្យបានម៉ត់ចត់ និងច្បាស់លាស់

៤.ត្រៀមរៀបចំកិច្ចប្រជុំជាមួយសហរដ្ឋអាម៉េរិក និងដៃគូពាក់ព័ន្ធឲ្យមានគុណភាព និងមានប្រសិទ្ធភាពខ្ពស់លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៥.ស្នើអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ធ្វើជាអង្គភាពនាំមុខ ចំណែកអគ្គស្នងការនគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋាន នៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រៀមចូលរួមកិច្ចប្រជុំឆ្លងខ្លឹមសាររបាយការណ៍របស់គណៈកម្មាធិការជាតិ ឲ្យមានភាពច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់

៦.ត្រៀមទឡ្ហីករបកស្រាយនូវអនុសាសន៍ដែលនៅសេសសល់ ដែលយើងមិនបានដាក់បញ្ចូល

៧.រៀបចំក្រុមការងារ ស្តីពី ផែនការប្រតិបត្តិការ ដែលមាន **ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ជាប្រធាន ជូនសម្តេចក្រឡាហោមចុះហត្ថលេខា ដើម្បីអនុវត្ត ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បញ្ជាក់បន្ថែមអំពីកិច្ចប្រជុំជាមួយសហរដ្ឋអាមេរិក និងដៃគូពាក់ព័ន្ធ ត្រូវរៀបចំឲ្យបានល្អ និងត្រៀមលក្ខណៈឲ្យបានគ្រប់ជ្រុងជ្រោយ ហើយអាចកំណត់ថ្ងៃប្រជុំគួរយកចុង ខែសីហា ឬ ដើមខែកញ្ញា ឆ្នាំ២០២២ ខាងមុខនេះ ។

ចុងបញ្ចប់ នៃកិច្ចប្រជុំ **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) មានប្រសាសន៍ថ្លែងអំណរគុណចំពោះការចូលរួម និងការបញ្ចេញមតិយោបល់របស់ ឯកឧត្តម លោកជំទាវ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។ សម្តេចក្រឡាហោម មានប្រសាសន៍ជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ជួបប្រទះ តែសេចក្តីសុខ សេចក្តីចម្រើន ទទួលបាននូវជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងបួនប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

កំណត់ហេតុបានបញ្ចប់នៅវេលាម៉ោងដប់មួយ និងសូន្យនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល។

ថ្ងៃពុធ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២
**អ្នកធ្វើកំណត់ហេតុ**

kamif

ឧត្តមសេនីយ៍ទោ. អ៊ឹម អាមិន្ទ

**គោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃ.......................... ខែ..............ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ..........ឆ្នាំ២០២២
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯករដ្ឋ.ប៉ុណ្ណា សំខាន់

05/09/22

ជូ_ប៊ុនអេង